ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

# តាងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

សំណុំរឿងរដ្ឋប្បវេណី បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នាថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០១២ ។

លេខ : ៥០៨

ចុះថ្ងៃទី ១៥-១១-២០១១

សាលដីកា

លេខ : ១១ "ក្រ.ស ស២"

ចុះថ្ងៃទី ៣១-០៥-២០១២

### សមាសភាពក្រុមប្រឹក្សា

- ឯកឧត្តម [redacted] ជាប្រធាន
- ឯកឧត្តម [redacted] ជាចៅក្រមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា

### ក្រឡាបញ្ជី

លោក [redacted]

- ដើមចោទឈ្មោះ [redacted] សារ៉ុត ភេទស្រី អាយុ ៦៣ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃភូមិហៃសាន ឃុំជ្រៃ ស្រុកថ្មគោល ខេត្តបាត់ដំបង ។ (ចុងបណ្ដឹងឧទ្ធរណ៍)

- ចុងចម្លើយឈ្មោះ [redacted] យុន ភេទស្រី អាយុ ៧៦ឆ្នាំ ជាតិខ្មែរ មុខរបរជាង ទីលំនៅសព្វថ្ងៃភូមិហៃសាន ឃុំជ្រៃ ស្រុកថ្មគោល ខេត្តបាត់ដំបង ។ (ដើមបណ្ដឹងឧទ្ធរណ៍)

មានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយ ។

### ខ្លឹមសារនៃការទាមទារ

ដើមចោទប្ដឹងទាមទារឱ្យតុលាការចេញសាលក្រម :

- សុំគ្រប់គ្រងលើដីទំហំ ២៩៩ ម៉ែត្រក្រឡា ជាកម្មសិទ្ធិ មានព្រំប្រទល់ខាងជើងទល់ឈ្មោះ [redacted] អន ខាងត្បូង ទល់ឈ្មោះ [redacted] សោភា ផ្លូវជាតិលេខ ៥ ខាងកើតទល់ឈ្មោះ [redacted] សារ៉ុត ខាងលិចទល់ឈ្មោះ [redacted] សោភា ស្ថិតនៅ ភូមិហៃសាន ឃុំជ្រៃ ស្រុកថ្មគោល ខេត្តបាត់ដំបង ។

- សុំឱ្យឈ្មោះ [redacted] យុន រុះរើផ្ទះចេញពីដីទំនាស់ ។

- ឱ្យចុងចម្លើយជាអ្នកទទួលបន្ទុកប្រាក់ប្រដាប់ក្ដី ។

ចុងចម្លើយប្ដឹងទាមទារឱ្យតុលាការចេញសាលក្រម :

- សុំលុបចោលការទាមទាររបស់ដើមចោទក្នុងពាក្យបណ្ដឹង ចុះថ្ងៃទី ២៨ ខែមីនា ឆ្នាំ២០១១ ទាំងមូល ។

- សុំឱ្យតុលាការរក្សានូវសេចក្ដីសម្រេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិលេខ ០១៤ គសជ/សសរ ចុះថ្ងៃ ទី០៨ ខែកុម្ភៈ ឆ្នាំ២០១១ ទុកជាបានការតាមច្បាប់ទាំងមូល ។





Scanned with CamScanner

- សុំគ្រប់គ្រងលើដីទំហំ ១៥០ ម៉ែត្រក្រឡា ជាកម្មសិទ្ធិ មានព្រំប្រទល់ខាងជើងទល់ឈ្មោះ [redacted] អន ខាងត្បូង ទល់ផ្លូវជាតិលេខ ៥ ខាងកើតទល់ឈ្មោះ [redacted] ជឿម និងប្រពន្ធឈ្មោះ [redacted] សារ៉ុត ខាងលិចទល់ឈ្មោះ [redacted] មឿន ស្ថិតនៅ ភូមិហៃសាន ឃុំជ្រៃ ស្រុកថ្មគោល ខេត្តបាត់ដំបង។

- ទាមទារជម្ងឺចិត្តខាតបង់ពេលវេលាចំនួន ៥០០០ដុល្លារអាមេរិក។

- ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ។

## អង្គហេតុ និងចំណុចវិវាទ

តាមពាក្យបណ្តឹង ចុះថ្ងៃទី ២៨ ខែមីនា ឆ្នាំ២០១១ របស់ដើមចោទឈ្មោះ [redacted] សារ៉ុត បានប្តឹងសុំឱ្យតុលាការចេញសាលក្រមសម្រេច សុំគ្រប់គ្រងលើដីទំហំ ២៩៩ ម៉ែត្រក្រឡា ជាកម្មសិទ្ធិ មានព្រំប្រទល់ខាងជើងទល់ឈ្មោះ [redacted] អន ខាងត្បូង ទល់ឈ្មោះ [redacted] សោភា ផ្លូវជាតិលេខ ៥ ខាងកើតទល់ឈ្មោះ [redacted] សារ៉ុត ខាងលិចទល់ឈ្មោះ [redacted] សោភា ស្ថិតនៅភូមិហៃសាន ឃុំជ្រៃ ស្រុកថ្មគោល ខេត្តបាត់ដំបង សុំឱ្យឈ្មោះ [redacted] យុន រុះរើផ្ទះចេញពីដីទំនាស់ឱ្យចុងចម្លើយ ជាអ្នកទទួលបន្ទុកប្រាក់ប្រដាប់ក្តី ដោយមូលហេតុថា នៅឆ្នាំ១៩៨៦ ខ្លួនបានទិញដីពីឈ្មោះ [redacted] សារឿន ដែលមានទំហំ ២៩៩ ម៉ែត្រក្រឡា ក្នុងតម្លៃ ១០០០០រៀល លុះដល់ឆ្នាំ១៩៨៧ ឈ្មោះ [redacted] យុន បានសុំខ្លួនស្នាក់នៅបណ្តោះអាសន្នទំរាំដល់ថ្ងៃស្លាប់ ដោយគាត់មិនហ៊ានរស់នៅលើដីកម្មសិទ្ធិរបស់គាត់ ដែលនៅពីក្រោយដីរបស់ខ្លួន ដោយបារម្ភណ៍ខ្លាចក្រែងមានការឈឺថ្កាត់យប់ព្រលប់ ព្រោះគ្មានកូនចៅមើលថែទេ។ លុះដល់ឆ្នាំ១៩៨៩ ខ្លួនបានធ្វើពាក្យកាន់កាប់ដីទំនាស់ព្រម ទាំងដីកម្មសិទ្ធិរបស់ខ្លួន សរុបទាំងអស់ ៨០០ម៉ែត្រក្រឡា។ ពេលនោះខ្លួនមិនបានចាប់អារម្មណ៍ថា ឈ្មោះ [redacted] យុន បាន ធ្វើពាក្យស្នើសុំកាន់កាប់លើដីទំនាស់នេះឬអត់ទេ ខ្លួនក៏ចេះតែឱ្យគាត់រស់នៅបន្តជាបណ្តោះអាសន្ន។ ក្រោយមកខ្លួនបានឱ្យឈ្មោះ [redacted] យុន ចេញពីដីទំនាស់ ស្រាប់តែឈ្មោះនេះមិនព្រមចាកចេញ ខ្លួនក៏ប្តឹងមកតុលាការតែម្តង។

តាមពាក្យបណ្តឹងតប ចុះថ្ងៃទី ២៦ ខែឧសភា ឆ្នាំ២០១១ របស់ចុងចម្លើយឈ្មោះ [redacted] យុន ប្តឹងសុំឱ្យតុលាការចេញសាលក្រមសម្រេច សុំលុបចោលការទាមទាររបស់ដើមចោទក្នុងពាក្យបណ្តឹង ចុះថ្ងៃទី ២៨ ខែមីនា ឆ្នាំ២០១១ ទាំងមូល សុំឱ្យតុលាការរក្សាទុវសេចក្តីសម្រេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិលេខ ០១៤ គសជ/សសរ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១១ ទុកជាបានការតាមច្បាប់ទាំងមូល សុំគ្រប់គ្រងលើដីទំហំ ១៥០ ម៉ែត្រក្រឡា ជាកម្មសិទ្ធិ មានព្រំប្រទល់ខាងជើងទល់ឈ្មោះ [redacted] អន ខាងត្បូង ទល់ផ្លូវជាតិលេខ ៥ ខាងកើតទល់ឈ្មោះ [redacted] ជឿម និងប្រពន្ធឈ្មោះ [redacted] សារ៉ុត ខាងលិចទល់ឈ្មោះ [redacted] មឿន ស្ថិតនៅ ភូមិហៃសាន ឃុំជ្រៃ ស្រុកថ្មគោល ខេត្តបាត់ដំបង ទាមទារជម្ងឺចិត្តខាតបង់ពេលវេលាចំនួន ៥០០០ដុល្លារអាមេរិក និងប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ ដោយមូលហេតុថា ការលើកឡើងក្នុងពាក្យបណ្តឹងរបស់ដើមចោទពុំពិតទេ ហើយការរស់នៅរបស់ខ្លួននៅភូមិហៃសាន គឺចាប់តាំងពីឆ្នាំ១៩៧៩មក ចំណែកភាគីដើមចោទបានរស់នៅលើដីជាប់ព្រំប៉ែកខាងកើតព្រំដីរបស់ខ្លួននៅឆ្នាំ១៩៨៦ ការចោទប្រកាន់ថា ខ្លួនសុំដីដើមចោទរស់នៅបណ្តោះអាសន្ននោះពុំពិតទេ គឺដើមចោទជាអ្នករំលោភបំពានយកដីរបស់ខ្លួនដែលខ្លួនបានកាន់កាប់តាំងពីឆ្នាំ១៩៧៩ រហូតដល់បច្ចុប្បន្ននេះ ឯដើមចោទបានមករស់នៅក្រោយខ្លួន។





Scanned with CamScanner

## ការអះអាងរបស់គូភាគី

## នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់

- ដើមចោទឈ្មោះ [redacted] សារ៉ុត (វត្តមាន). - ចុងចម្លើយឈ្មោះ [redacted] យុន (អវត្តមាន)
- លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយ(វត្តមាន)

- ដើមចោទឈ្មោះ [redacted] សារ៉ុត ថ្លែងការណ៍ថា: ខ្លួនសំណូមពរ សុំកាន់កាប់ប្រើប្រាស់លើដីចំណីផ្លូវ ដែលមានរោងជួសជុលម៉ូតូនោះជាបណ្តោះអាសន្ន ព្រោះអីនៅតំបន់នោះប្រជាពលរដ្ឋប្រើប្រាស់ផ្លូវសាធារណៈនោះស្ទើរតែគ្រប់គ្រួសារ តែមិនទាន់ឃើញមានការជូនដំណឹងណាមួយពីអាជ្ញាធរមានសមត្ថកិច្ចឱ្យរុះរើទេ ម្យ៉ាងទៀត រោងជួសជុលម៉ូតូរបស់ខ្លួននោះបានសង់តាំងពីឆ្នាំ១៩៨៧ មកម្ល៉េះ។ មកដល់ពេលនោះខ្លួនសុខចិត្តទុកដីប្រវែង ២ម៉ែត្រ នៅផ្នែកខាងលិចដីរបស់ខ្លួនដើម្បីឱ្យចុងចម្លើយ និងប្រជាពលរដ្ឋនៅក្បែរខាងនោះអាចឆ្លងកាត់ទៅកាន់ផ្លូវជាតិបាន ខ្លួនសន្យាថា នឹងរុះរើរោងជួសជុលម៉ូតូនោះចេញភ្លាម នៅពេលណាមានការជូនដំណឹងពីអាជ្ញាធរមានសមត្ថកិច្ចឱ្យរុះរើដើម្បីអភិវឌ្ឍន៍ ឬពង្រីកផ្លូវនៅទីនោះ ឬក៏ជាប្រយោជន៍សាធារណៈណាមួយដែលបានតម្រូវដោយមិនមានការតវ៉ាអ្វីទេ។

- លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយ ធ្វើសេចក្តីថ្លែងការណ៍ថា: សេចក្តីសម្រេចលេខ ០១៤ គសជ ចុះថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ២០១១ របស់គណៈកម្មការសុរិយោដីថ្នាក់ជាតិបានសម្រេចរួចហើយកូនក្តីខ្លួនសុំគ្រប់គ្រងដីជាកម្មសិទ្ធិទំហំ ១៥០ម៉ែត្រក្រឡា មានព្រំប្រទល់ខាងជើងទល់នឹងដីឈ្មោះ [redacted] អន ខាងត្បូងទល់នឹងផ្លូវជាតិលេខ ៥ ខាងកើតទល់នឹងដីឈ្មោះ [redacted] ជឿម និងប្រពន្ធឈ្មោះ [redacted] សារ៉ុត និងខាងលិចទល់នឹងដីឈ្មោះ [redacted] មឿន ដែលមានទីតាំងស្ថិតនៅភូមិហៃសាន ឃុំជ្រៃ ស្រុកថ្មគោល ខេត្តបាត់ដំបង។ សំណូមពរ សុំលុបចោលនូវសេចក្តីសម្រេចរបស់សាលាដំបូងខេត្តបាត់ដំបង ក្នុងសាលក្រមរដ្ឋប្បវេណីលេខ ១៩ ង ចុះថ្ងៃទី ២២ ខែកក្កដា ឆ្នាំ២០១១ ត្រង់ចំណុចទី ១ (ក) និង (ខ) និងចំណុចទី ២ ទី ៣ និងទី ៤ និងស្នើសុំតម្កល់សេចក្តីសម្រេចលេខ ០១៤ គសជ/សសរ ចុះថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ២០១១ ·របស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ហើយនិងសុំសម្រេចតាមពាក្យបណ្តឹងតបរបស់កូនក្តីឈ្មោះ [redacted] យុន ចុះថ្ងៃទី ២៦ ខែឧសភា ឆ្នាំ២០១១។

## សំអាងហេតុ និង សេចក្តីបញ្ជប់

## សាលាឧទ្ធរណ៍ យល់ឃើញថា:

១- បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ០២ ខែសីហា ឆ្នាំ២០១១ របស់លោកមេធាវី [redacted] ប្តឹងឧទ្ធរណ៍នឹងសាលក្រមរដ្ឋប្បវេណីលេខ ១៩ ង ចុះថ្ងៃទី ២២ ខែកក្កដា ឆ្នាំ២០១១ របស់សាលាដំបូងខេត្តបាត់ដំបង ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច បានធ្វើឡើងត្រឹមត្រូវតាមកំណត់ច្បាប់ យោងតាមមាត្រា ២៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី សាលាឧទ្ធរណ៍ទទួលទាញហេតុផលដោយផ្ទាល់មាត់។

២- តាមលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់ ឃើញថា សាលក្រមរដ្ឋប្បវេណីលេខ ១៩ ង ចុះថ្ងៃទី ២២ ខែកក្កដា ឆ្នាំ២០១១ របស់សាលាដំបូងខេត្តបាត់ដំបង ដែលសម្រេចមកនេះមានលក្ខណៈត្រឹមត្រូវតាមច្បាប់ហើយ គួរសាលាឧទ្ធរណ៍តម្កល់ទុកជាបានការតាមច្បាប់ ដោយហេតុថា តាមតំនូសប្លង់ទីតាំងដីទំនាស់ ចុះថ្ងៃទី





Scanned with CamScanner

១១ ខែមករា ឆ្នាំ២០០៤ របស់ការិយាល័យរៀបចំដែនដីនគរូបនីយកម្ម សំណង់ និងភូមិបាលស្រុកបញ្ជាក់ថា ដីទំហំ ១៩៨ម៉ែត្រការ៉េ មានចម្ងាយ ៣០ម៉ែត្រ ពីអ័ក្សផ្លូវជាតិលេខ ៥ និងតាមសេចក្តីប្រកាសលេខ ០៦ ប្រក ចុះថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ១៩៩៩ របស់រាជរដ្ឋាភិបាលបានកំណត់ដីចំណីផ្លូវជាតិលេខ ៥ មានចម្ងាយ ៣០ម៉ែត្រ ពីអ័ក្សផ្លូវជាតិ និងតាមសេចក្តីសម្រេចលេខ ០១៤ គសជ/សសរ ចុះថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ២០០៨ របស់គណៈកម្មការស៊ុរិយោដីថ្នាក់ជាតិ បានសម្រេចរក្សាដីទំនាស់ទំហំ ១៩៨ម៉ែត្រការ៉េ ទុកជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងដោយផ្អែកលើអត្ថិភាពនៃការប្តឹងទាមទាររបស់ដើមចោទ និងបណ្តឹងតបរបស់ចុងចម្លើយ គួរសាលាឧទ្ធរណ៍ពិចារណាដូចមានក្នុងផ្នែកសំអាងហេតុនៃសាលក្រមរដ្ឋប្បវេណីរបស់សាលាដំបូងខេត្តបន្ទាយមានជ័យបញ្ជាក់ស្រាប់ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១- ច្រានចោលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ០២ ខែសីហា ឆ្នាំ២០១១ របស់មេធាវី [redacted] តំណាងដោយអាណត្តិរបស់ចុងចម្លើយ ។

២- តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ១៩ ង ចុះថ្ងៃទី ២២ ខែកក្កដា ឆ្នាំ២០១១ របស់សាលាដំបូងខេត្តបាត់ដំបង ទុកជាបានការ ។

៣- ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ ។

៤- សាលដីកានេះប្រកាសជាសាធារណៈនៅថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០១២ ។

បើកសិទ្ធិប្តឹងសាទុក្ខក្នុងអំឡុងពេល ០១ខែ ចាប់គិតពីថ្ងៃបានទទួលការបញ្ជូនសាលដីកានេះ ។

ក្រឡាបញ្ជី ចៅក្រមប្រឹក្សា ប្រធានក្រុមប្រឹក្សា

ហត្ថលេខា [redacted]

---

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ ថ្ងៃទី [illegible] ឆ្នាំ ២០១២

ក្រឡាបញ្ជី

[redacted]

បានឃើញ

ប្រធានក្រុមប្រឹក្សា

[redacted]



១៤៥

145

Scanned with CamScanner